ការចែកចាយ : មានកំណត់

២៥ កុម្ភៈ ២០១០

អត្ថបទដើម : ភាសាអង់គ្លេស

អត្ថបទពិនិត្យផ្ទៀងផ្ទាត់ចុងក្រោយបំផុត

**គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍**
**សម័យប្រជុំលើកទីចិតសិបប្រាំមួយ**
១៥ កុម្ភៈ ដល់ ១២ មីនា ២០១០

# ការពិនិត្យពិចារណាលើរបាយការណ៍ ដែលបានដាក់ជូនដោយរដ្ឋភាគីនានា ស្របតាមមាត្រា៩ នៃអនុសញ្ញានេះ

## ពង្រាងសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍

## កម្ពុជា

១. គណៈកម្មាធិការបានពិនិត្យពិចារណាលើរបាយការណ៍តាមកាលកំណត់ ចាប់ពីរបាយការណ៍ទីប្រាំបីដល់ទីដប់បីរបស់កម្ពុជា ដែលបានដាក់ជូនក្នុងឯកសារតែមួយ (CERD/C/KHM/8-13) នាសម័យប្រជុំរបស់ខ្លួនលើកទី១៩៨០ និងទី១៩៨១ (CERD/C/SR.1980 and 1981) ដែលបានធ្វើឡើងនៅថ្ងៃទី១៨ និងទី១៩ ខែកម្ភៈ ឆ្នាំ២០១០ ។ ក្នុងសម័យប្រជុំឆ្នាំ ១៩៩៨ របស់ខ្លួន (CERD/C/SR.1998) ដែលបានធ្វើឡើងនៅថ្ងៃទី៤ ខែមីនា ឆ្នាំ ២០១០ គណៈកម្មាធិការបានអនុម័តសេចក្តីសង្កេតនានាចុងក្រោយដូចតទៅ ៖

## ក. សេចក្តីផ្តើម

២. គណៈកម្មាធិការស្វាគមន៍របាយការណ៍តាមកាលកំណត់ដែលបានដាក់ជូនដោយកម្ពុជា និង ឱកាសដែលបានផ្តល់សំរាប់បន្តការពិភាក្សាជាមួយរដ្ឋភាគី ។ ដោយសំគាល់ឃើញថា របាយការណ៍នេះហួសកាលកំណត់ដាក់ជូនជាង១០ ឆ្នាំ (របាយការណ៍លើកទីប្រាំបីត្រូវដល់កាលកំណត់ក្នុងឆ្នាំ១៩៩៨) គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីគិតដល់កាល



Please recycle

កំណត់សំរាប់ដាក់ជូនរបាយការណ៍របស់ខ្លួននៅថ្ងៃខាងមុខ ដើម្បី បំពេញកាតព្វកិច្ចធ្វើរបាយការណ៍របស់ខ្លួនក្រោមសន្ធិសញ្ញានេះ ។

៣. គណៈកម្មាធិការសំដែងការកោតសរសើរដល់រដ្ឋភាគី ចំពោះការពិភាក្សាប្រកបដោយន័យស្ថាបនា និងកិច្ចខិតខំប្រឹងប្រែងរបស់គណៈប្រតិភូនៅទីក្រុងហ្សឺណែវ ដែលដឹកនាំដោយតំណាងអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ ក្នុងការឆ្លើយសំណួរដែលគណៈកម្មាធិការបានលើកឡើង។ គណៈកម្មាធិការ សំគាល់ឃើញថា គណៈប្រតិភូនេះ មិនមានតំណាងមកពីក្រសួង/មន្ទីរពាក់ព័ន្ធក្នុងប្រទេសកម្ពុជាទេ ដែលបានកំរិតលទ្ធភាពទទួលបានព័ត៌មាន ឬចំលើយទៅនឹ ងសំណួរដែលគណៈកម្មាធិការបានលើកឡើងក្នុងសម័យប្រជុំនេះ ។ ក្នុងការបង្ហាញខ្លួន លើកក្រោយ នៅចំពោះមុខគណៈកម្មាធិការ គណៈកម្មាធិការអញ្ជើញរដ្ឋភាគីបញ្ជូនអ្នកជំនាញផ្សេងៗពីកម្ពុជា ដើម្បីអាចឲ្យការពិភាក្សាមានលក្ខណៈហ្មត់ចត់ច្រើនជាងនេះថែមទៀត ។

៤. គណៈកម្មាធិការអបអរចំពោះការចូលរួមជាវិភាគទាន ដោយអង្គការក្រៅរដ្ឋាភិបាលកម្ពុជាជាច្រើន ដែលបានបង្កើនគុណភាពដល់ការពិភាក្សាជាមួយរដ្ឋភាគី ។

## ខ. កត្តា និងការលំបាកនានា ដែលរាំងដល់ការអនុវត្តន៍អនុសញ្ញានេះ

៥. គណៈកម្មាធិការសំគាល់ឃើញថា បច្ចុប្បន្ននេះ រដ្ឋភាគីកំពុងស្ថិតក្នុងដំណាក់កាលបន្តការកសាងប្រទេសឡើងវិញ ក្រោយពីមានជម្លោះប្រដាប់អាវុធមួយ ដែលពោរពេញទៅដោយការលំបាក និងដែលបានអូសបន្លាយពេលយ៉ាងយូរ និងសំគាល់ឃើញថា ប្រវត្តិកាលនៃសន្តិភាពផុយស្រួយ ទាំងនៅក្នុងប្រទេសទាំងនៅតាមព្រំដែនរបស់ខ្លួនបានរាំងដល់ការអនុវត្តន៍ពេញលេញនៃអនុសញ្ញានេះ ។

## គ. ចំណុចវិជ្ជមាន

៦. គណៈកម្មាធិការសំគាល់ឃើញនូវការដាក់បញ្ចូលសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាទៅក្នុងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា និងស្វាគមន៍សេចក្តីសំរេចចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញ (សេចក្តីសំរេចលេខ០៩២/០០៣/២០០៧) ដោយ

បញ្ជាក់ជាថ្មីថា ចៅក្រម ត្រូវបកស្រាយច្បាប់ និងធ្វើសេចក្តីសំរេច ផ្សេងៗផ្អែកលើកាតព្វ-កិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា ។

៧. គណៈកម្មាធិការស្វាគមន៍ផងដែរ ចំពោះការផ្តល់សច្ចាប័នលើពិធីសារបន្ថែមនៃអនុ-សញ្ញាប្រឆាំងទារុណកម្មក្នុងខែមេសា ឆ្នាំ២០០៧ និងការអនុម័តច្បាប់ស្តីពីការផ្តល់សច្ចា-ប័នលើពិធីសារបន្ថែមនៃអនុសញ្ញាបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ក្នុងខែសីហា ឆ្នាំ ២០០៩ ទាំងពីរនេះគឺជាជំហានដ៏សំខាន់បំផុតឈានទៅរកការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ។

៨. គណៈកម្មាធិការអបអរចំពោះវិធានការទាំងឡាយដែលរដ្ឋភាគីបានចាត់ ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់របស់ខ្លួន សំរាប់ការការពារនិងការលើកស្ទួយសិទ្ធិមនុស្ស ជាពិសេស ការអនុម័តក្រមនីតិវិធីព្រហ្មទណ្ឌក្នុងខែសីហា ឆ្នាំ២០០៧។

៩. គណៈកម្មាធិការកត់សំគាល់ដោយពេញចិត្ត ចំពោះការអនុម័តច្បាប់ភូមិបាលក្នុងឆ្នាំ ២០០១ ក៏ដូចជាអនុក្រឹត្យជាបន្តបន្ទាប់ ក្នុងគោលដៅការពារឲ្យកាន់តែប្រសើរឡើងថែមទៀតនូវសិទ្ធិដីធ្លីរបស់ក្រុមជនភាគតិច រាប់ទាំងជនជាតិដើមភាគតិចផង។

១០. គណៈកម្មាធិការកត់សំគាល់ដោយពេញចិត្ត ចំពោះការបង្កើតអង្គជំនុំជម្រះវិសា-មញ្ញក្នុងតុលាការកម្ពុជា(ECCC) ដោយសហការជាមួយអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ។ គណៈកម្មាធិការជំរុញលើកទឹកចិត្តដល់រដ្ឋ ភាគីឲ្យបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីនាំខ្លួនអ្នកប្រព្រឹត្តអំពើ សាហាវយង់ឃ្នងក្នុងរបបខ្មែរក្រហមទៅតុលាការ ដើម្បីផ្តន្ទាទោសទៅតាមច្បាប់ ។

## ឃ. កង្វល់ និងអនុសាសន៍

១១. គណៈកម្មាធិការស្វាគមន៍នូវការអនុម័តក្រមព្រហ្មទណ្ឌកាលពីពេលថ្មីៗនេះ និងបញ្ញត្តិនានានៃក្រមនេះស្តីពីបទល្មើសប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងបទល្មើសប្រឆាំងនឹងសន្តិសុខសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការមាន

កង្វល់អំពីអវត្តមាននិយមន័យច្បាស់លាស់អំពីទង្វើដែលបង្កើតការរើសអើងពូជសាសន៍ក្រោមច្បាប់កម្ពុជា (មាត្រា ១ និងមាត្រា២) ។

**គណៈកម្មាធិការផ្តល់អនុសាសន៍ថា ច្បាប់នេះគួរតែបានបំពេញបង្គ្រប់ ដើម្បីធានាឲ្យមាននិយមន័យច្បាស់លាស់ចំពោះការរើសអើងពូជសាសន៍ ស្របតាមមាត្រា ១ នៃអនុសញ្ញានេះ និងសិទ្ធិបុគ្គលគ្រប់រូប មិនត្រូវបានគេរើសអើងប្រឆាំង ក្នុងការអាស្រ័យផលនូវសិទ្ធិទាំងអស់ដែលមានចែងក្នុងមាត្រា៥ នៃអនុសញ្ញានេះ។ គណៈកម្មាធិការផ្តល់អនុសាសន៍ថែមទៀតថា រដ្ឋភាគីត្រូវធានាថាបញ្ញត្តិទាំងអស់នេះ ត្រូវបានផ្សព្វផ្សាយឲ្យសាធារណៈជនបានយល់ដឹងទាំងស្រុង និងត្រូវបានដាក់ឲ្យអនុវត្ត។**

១២. គណៈកម្មាធិការស្វាគមន៍ការផ្តល់ព័ត៌មានដោយរដ្ឋភាគីស្តីពីភាសា និងសមាសភាពនៃប្រជាពលរដ្ឋជាតិពន្ធុ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការមានកង្វល់ថា ព័ត៌មានដែលបានផ្តល់ មិន អាចស្វែងយល់ស៊ីជម្រៅបានដល់ស្ថានភាព ជាពិសេស ជនភាគតិចជាតិពន្ធុ ។

**ស្របតាមអនុសាសន៍ទូទៅរបស់ខ្លួនលេខ៨ (១៩៩០) និងតាមកថាខ័ណ្ឌទី១០ ដល់ទី១២ នៃគោលការណ៍ណែនាំអំពីការធ្វើរបាយការណ៍ សំរាប់ឯកសារជាក់លាក់ CERD ដែលបានអនុម័តនាសម័យប្រជុំលើកទីចិតសិបមួយរបស់ខ្លួន(CERD/C/2007/1) គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីដាក់បញ្ចូលទៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវទិដ្ឋន័យបំបែកស្តីពីជនភាគតិចជាតិពន្ធុរបស់រដ្ឋភាគី រាប់ទាំងជនជាតិដើមភាគតិច និងទិន្នន័យស្តីពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេ។**

១៣. ដោយទទួលស្គាល់ថា នីតិរដ្ឋ ជាគ្រឹះសំរាប់ការពារសិទ្ធិដែលមានចែងក្នុងអនុសញ្ញានេះ គណៈកម្មាធិការមានកង្វល់ ចំពោះរបាយការណ៍ដែលថា មានការជ្រៀតជ្រែកខាងនយោបាយ និងអំពើពុករលួយដែល ធ្វើឲ្យប៉ះពាល់ដល់ស្ថាប័នតុលាការ ក៏ដូចជាការប្រ - ព្រឹត្តទៅនៃសេវាសាធារណៈមួយចំនួន។ ម្យ៉ាងវិញទៀត គណៈកម្មាធិការទទួលស្គាល់ និងស្វាគមន៍ដំណើរការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ក៏ប៉ុន្តែគណៈកម្មាធិការជឿថា ច្បាប់ដូចនេះ ត្រូវការការអនុវត្តន៍ឲ្យបានពេញលេញ ហើយត្រូវមានយន្តការមួយចំនួន (មាត្រា ២) ដើម្បីដំណើរការ។

**គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីបន្ត និងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីពង្រឹងនិងធានាឯករាជ្យភាពតុលាការ ហើយធានាថា ស្ថាប័ននេះមិនត្រូវបានត្រួតត្រានិងជ្រៀតជ្រែកខាងនយោបាយ តាមរយៈការអនុម័តឲ្យបានឆាប់រហ័សនូវច្បាប់ទាំងអស់ដែលពាក់ព័ន្ធដល់ការធ្វើកំណែទម្រង់ ។ គណៈកម្មាធិការផ្តល់អនុសាសន៍ទៀតថា រដ្ឋភាគីចាត់វិធានការ ដើម្បីបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការស៊ើបអង្កេត និងចាត់វិធានការដាក់វិន័យក្នុងករណីអសមត្ថភាព និងអំពើពុករលួយ ។**

១៩. ទន្ទឹមនឹងការស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋភាគីក្នុងការអនុម័តច្បាប់ជាច្រើនក្នុងវិស័យមួយចំនួនដូចជា សិទ្ធិជ្រកកោន សិទ្ធិដីធ្លី សិទ្ធិអប់រំ ការហាមប្រាមការរើសអើងពូជសាសន៍ គណៈកម្មាធិការមានកង្វល់អំពីការខ្វះការអនុវត្តន៍ និងការពង្រឹងអនុវត្តច្បាប់ទាំងនេះជាឯកសណ្ឋាននិងដោយសុទ្ធចិត្ត។ អាស្រ័យហេតុនេះ គណៈកម្មាធិការកត់សំ - គាល់ដោយកង្វល់ជាពិសេសថា ដូច ដែលបានលើកឡើងក្នុងសេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០០៩ រដ្ឋភាគីបានសំរេចបញ្ជូនជាតិពន្ធុអ៊ុយហ្គ័រ ២០ នាក់ចេញពីប្រទេសកម្ពុជានៅមុនការបញ្ចប់ដំណើរការសំរេចពីឋានៈជនភៀសខ្លួន ដូច្នេះធ្វើឲ្យរារាំងដល់ការសំរេចតាមសត្យានុម័តមួយ អំពីថាតើអ្នកដែលគេបញ្ជូនទៅនោះត្រូវប្រឈម ឬទេនឹងហានិភ័យនៃការធ្វើទុក្ខបុកម្នេញ ឬរូបភាពផ្សេងទៀតនៃការប្រព្រឹត្តមិនគប្បីមកលើខ្លួន (មាត្រា២ និងមាត្រា ៥)។

**គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីធាថាថា ច្បាប់ដែលបាន អនុម័តហើយ រាប់ទាំងច្បាប់ស្តីពីសិទ្ធិជ្រកកោន ត្រូវ តែបានអនុវត្តយ៉ាងពេញលេញ និងសុទ្ធចិត្ត ដើម្បីផ្តល់ការការពារទាំងស្រុងតាមផ្លូវច្បាប់ ការគោរពគោលការណ៍ស្តីពី "ការមិនបញ្ជូនត្រឡប់វិញ" និងការទទួលបានដូចគ្នានូវសិទ្ធិ និងអត្ថប្រយោជន៍ស្មើភាពគ្នា។**

១៥. ទន្ទឹងនឹងសំគាល់ឃើញថា រដ្ឋភាគីមានយន្តការសិទ្ធិមនុស្សមួយចំនួនក្នុងស្ថាប័នផ្សេងៗនៃរដ្ឋាភិបាលរបស់ខ្លួន គណៈកម្មាធិការនៅតែមានកង្វល់ថា ស្ថាប័នជាតិសិទ្ធិមនុស្សឯករាជមួយ នៅមិនទាន់ត្រូវបានបង្កើតនៅឡើយទេ (មាត្រា ២) ។

**គណៈកម្មាធិការជំរុញលើកទឹកចិត្តរដ្ឋភាគីបង្កើតស្ថាប័នសិទ្ធិមនុស្សឯករាជ្យមួយស្របតាមគោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិសំរាប់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស (គោលការណ៍ទីក្រុងប៉ារីស) ( សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ ៤៨/១៣៤)។ អាស្រ័យហេតុនេះ គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋាភិបាលពិគ្រោះ**

យោបល់ជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា និងពិចារណាការទទួលយកជំនួយផ្នែកបច្ចេកទេស ដើម្បីពង្រឹងជាថ្មីនូវកិច្ចខិតខំប្រឹងជាបន្ត ដើម្បីតាក់តែងច្បាប់មួយស្តីពីការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ស្របទាំងស្រុងទៅនឹងគោលការណ៍ទីក្រុងប៉ារីស ។

១៦. គណៈកម្មាធិការទទួលស្គាល់អំពីសន្ទុះនៃការរីកចំរើនខ្លាំងផ្នែកសេដ្ឋកិច្ចនាពេលថ្មីៗនេះរបស់រដ្ឋភាគី និងអំពីអត្ថប្រយោជន៍នៃការរីកចំរើននេះចំពោះប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការមានកង្វល់ថា ដំណើរស្វែងរកភាពរុងរឿង និងការរីកចំរើនផ្នែកសេដ្ឋកិច្ច នៅតែបន្តមានក្នុងករណីខ្លះ ជាឧបសគ្គដល់សហគមន៍មួយចំនួនដែលងាយរងគ្រោះ ដូចជាសហគមន៍ជនជាតិដើមភាគតិច ។ គណៈកម្មាធិការមានកង្វល់ជាពិសេស អំពីសេចក្តីរាយការណ៍ទាក់ទងនឹងការផ្តល់យ៉ាងឆាប់រហ័សនូវសម្បទាន ផ្សេងៗលើដីធ្លីដែលជនជាតិដើមភាគតិចកាន់កាប់ជាប្រពៃណី ដោយមិនគិតគូរគ្រប់ជ្រុងជ្រោយ ឬមិនប្រើប្រាស់អស់នីតិវិធី ដែលមានចែងក្នុងច្បាប់ភូមិបាល និងអនុក្រឹត្យនានាដែលពាក់ព័ន្ធ (មាត្រា ២ និងមាត្រា ៥) ។

គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីធានាឲ្យមានតុល្យភាពមួយសមស្រប រវាងការអភិវឌ្ឍន៍ និងសិទ្ធិពលរដ្ឋរបស់ខ្លួនត្រូវបានទទួល និងធានាថាការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួនមិនត្រូវធ្វើឲ្យខាតបង់សិទ្ធិក្រុម ឬបុ គ្គលដែលងាយរងគ្រោះដូចមានចែងក្នុងអនុសញ្ញានេះឡើយ ។ គណៈកម្មាធិការផ្តល់អនុសាសន៍ទៀតថា រដ្ឋភាគីតាក់តែងវិធានការសមស្រប ស្តីពីការបង្ការ ដូចជា:(១) ការពន្យាពេលផ្តល់សម្បទានលើដីធ្លីដែលសហគមន៍ជនជាតិដើមភាគតិចរស់នៅ ដែលគាត់បានដាក់ពាក្យសុំចុះបញ្ជីតាមផ្លូវច្បាប់ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី (២) ការផ្តល់ដីសម្បទានត្រូវរង់ចាំដល់ការចេញប័ណ្ណកម្មសិទ្ធិសម្ហូភាព និងសិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងការកាន់កាប់ការអភិវឌ្ឍន៍ ការគ្រប់គ្រង និងការប្រើប្រាស់ដីសហគមន៍របស់ខ្លួនត្រូវបានផ្តល់ ៣-ការផ្តល់សម្បទានអាចធ្វើបាននៅតំបន់ដែលមានការវាយតំលៃ និង ការពិគ្រោះយោបល់ដោយការយល់ព្រមពីជនជាតិដើមភាគតិច និងដោយគ្មានការបោកបន្លំ ឬដែលគាត់បានដឹងច្បាស់ពីផលវិបាក នៅថ្ងៃអនាគត ។

គណៈកម្មាធិការបន្តជំរុញលើកទឹកចិត្តដល់ក្រុមហ៊ុនសាជីវកម្មទាំងអស់ថា នៅពេលចូលពាក់ព័ន្ធក្នុងបញ្ហាសម្បទានដីសេដ្ឋកិច្ច ត្រូវគិតគូរអំពីការទទួលខុសត្រូវផ្នែកសង្គមរបស់ក្រុមហ៊ុន ព្រោះការងារនេះវាទាក់ទងដល់សិទ្ធិ និងសុខមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន ។

១៧. គណៈកម្មាធិការមានកង្វល់ចំពោះរបាយការណ៍អំពីការបំភិតបំភ័យ និងអំពើហឹង្សាប្រឆាំងនឹងជនជាតិដើមភាគតិចក្នុងកំឡុងពេលនៃការបណ្តេញចេញដោយបង្ខំ ឬក្នុងការទំនាស់ដីធ្លីដែល ប៉ះពាល់ដល់ពួកគាត់ ។ គណៈកម្មាធិការមានកង្វល់ផងដែរ ចំពោះ របាយការណ៍អំពីនិន្នាការដាក់គំនាប ចោទប្រកាន់ និងចាប់ខ្លួនអ្នកភូមិជនជាតិដើមភាគតិច នៅពេលដែល ពួកគាត់តវ៉ាប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ឬតវ៉ាចំពោះការ ផ្តល់សម្បទានលើដី របស់ជនជាតិដើមភាគតិច (មាត្រា ៦)។

**គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យផ្តល់ការការពារពេញលេញដល់ក្រុមជនងាយរងគ្រោះ ប្រឆាំងនឹងការវាយប្រហារលើរូបកាយ និងការបំភិតបំភ័យ នៅពេលដែលពួកគាត់ព្យាយាមប្រើប្រាស់សិទ្ធិរបស់ខ្លួនទាក់ទងនឹងដីសហគមន៍ ។ គណៈកម្មាធិការស្នើយ៉ាងទទូចដល់រដ្ឋភាគីឲ្យនាំខ្លួនអ្នកប្រព្រឹត្តល្មើសទៅតុលាការ ដើម្បីផ្តន្ទាទោសទៅតាមច្បាប់ ។ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីពង្រឹ ងប្រព័ន្ធយុត្តិធម៌ រដ្ឋភាគីគួរធានាប្រសិទ្ធិភាពថែមទៀតដល់ប្រព័ន្ធយុត្តិធម៌ ដើម្បីធានាសិទ្ធិស្មើគ្នាក្នុងការស្វែងរកយុត្តិធម៌សំរាប់មនុស្សគ្រប់រូប រាប់ទាំងជនភាគតិច និងជនជាតិដើមភាគតិច ។ អនុលោមតាមអនុសាសន៍ទូទៅលេខ៣១ (២០០៥) របស់គណៈកម្មាធិការស្តីពីការបង្ការការរើសអើងពូជសាសន៍ ក្នុងការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។**

១៨. ទន្ទឹមនឹងសំគាល់ឃើញថា រដ្ឋភាគីបានអះអាងច្រើនលើកច្រើនសារថា ខ្មែរក្រោមត្រូវបានចាត់ទុកថាជាពលរដ្ឋខ្មែរ គណៈកម្មាធិការមានកង្វល់ថា ដំណើរការសំរាប់ខ្មែរក្រោមម្នាក់ៗដាក់ពាក្យសុំឯកសារសញ្ជាតិរបស់ខ្លួន មានការលំបាកច្រើនជាងសំរាប់ពលរដ្ឋខ្មែរដទៃទៀត ។ គណៈកម្មាធិការមានកង្វល់ទៀតថា ការបញ្ជាក់ឯកសារសញ្ជាតិខ្មែររបស់ខ្មែរក្រោមម្នាក់ៗត្រូវបានអូសបន្លាយពេលវេលា ឬបដិសេធ ដែលធ្វើឲ្យពួកគាត់មិនទទួលបានសិទ្ធិនិងអត្ថប្រយោជន៍ពេញលេញនិងស្មើគ្នា ដូចមានចែងក្នុងរ ដ្ឋធម្មនុញ្ញ និងច្បាប់របស់រដ្ឋភាគី (មាត្រា ៥) ។

**គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីធានាថា ខ្មែរក្រោមគ្រប់រូបដែលសុំបញ្ជាក់ឯកសារសញ្ជាតិរបស់ខ្លួន អាចទទួលបានអត្តសញ្ញាប័ណ្ណសញ្ជាតិទាន់ពេលវេលា និងស្ថិតក្រោមនីតិវិធីស្មើគ្នា និងដូចគ្នា ដែលមានសារសំខាន់ចំពោះបុគ្គលគ្រប់រូប ដែលគេចាត់ទុកថាជាពលរដ្ឋខ្មែរ ។**

១៩. គណៈកម្មាធិការបានទទួលព័ត៌មានថា ក្នុងការដាក់ពាក្យសុំឯកសារ /អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ខ្មែរក្រោមត្រូវបានគេតម្រូវ ឬបង្ខំឲ្យផ្លាស់ប្តូរព័ត៌មានសំខាន់ៗមួយចំនួនដូចជា ឈ្មោះ និងទីកន្លែងកំណើត ដើម្បីទទួលបានឯកសារនោះ (មាត្រា៥) ។

**ដោយយល់ឃើញថា ឈ្មោះបុគ្គលម្នាក់ៗ គឺជាផ្នែកមួយដ៏សំខាន់នៃអត្តសញ្ញាណវប្បធម៌ និងជាតិពន្ធុ ហើយថា ជីវប្រវត្តិផ្ទាល់ខ្លួន រាប់ទាំងថ្ងៃខែឆ្នាំកំណើត និងទីកន្លែងកំណើតក៏ជាផ្នែកមួយនៃអត្តសញ្ញាណដែរ គណៈកម្មាធិការផ្តល់អនុសាសន៍យ៉ាងខ្លាំងថា រដ្ឋភាគី ចាត់វិធានការចាំបាច់ ដើម្បីធានាថា ខ្មែរក្រោមដែលសុំបញ្ជាក់សញ្ជាតិរបស់ខ្លួន មានសិទ្ធិពេញលេញក្នុងការចុះឈ្មោះ និងទីកន្លែងកំណើតពិតប្រាកដរបស់ខ្លួន តាមការជ្រើសរើសរបស់គាត់ ។**

២០. ទន្ទឹមនឹងសំគាល់ឃើញកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការអនុវត្តន៍កម្មវិធីអប់រំជាតិរបស់ខ្លួន "ការអប់រំសំរាប់មនុស្សគ្រប់រូប" គណៈកម្មាធិការមានកង្វល់អំពីភាពផ្សេងគ្នានៃសិទ្ធិទទួលបានការអប់រំ ជាពិសេស នៅតំបន់ដាច់ស្រយាល ។ គណៈកម្មាធិការ មានកង្វល់ជាពិសេស ចំពោះការអប់រំសំរាប់កុមារនៅតំបន់មួយចំនួនដូចជា ខេត្តមណ្ឌល គីរី និងរតនគីរី ដែលប្រជាពលរដ្ឋរស់នៅទីនោះ ភាគច្រើនជាជនភាគតិច និងជនជាតិដើមភាគតិច ។ គណៈកម្មាធិការមានកង្វល់ថា អត្រាចុះឈ្មោះ និងការទទួលសិស្សឲ្យចូលរៀន មានចំនួនទាបជាងនៅថ្នាក់ជាតិ ហើយអត្រាសិស្សរៀនត្រួតថ្នាក់ និងអត្រាសិស្សបោះបង់ចោលការសិក្សាមានកំរិតខ្ពស់ជាងនៅថ្នាក់ជាតិ គិតជាមធ្យមភាគ (មាត្រា ២ និង មាត្រា ៥) ។

**គណៈកម្មាធិការផ្តល់អនុសាសន៍ឲ្យរដ្ឋភាគីបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសំរេចគោលដៅរបស់ខ្លួនស្តីពី"ការអប់រំសំរាប់មនុស្សគ្រប់រូប និងគិតគូរអំពីកម្មវិធីអប់រំពីរភាសា តាមការគួរ នៅតំបន់ដាច់ស្រយ៉ាល ជាមធ្យោ បាយនៃការពង្រឹងបរិស្ថានសិក្សាសំរាប់ជនភាគតិចជាតិពន្ធុ និងជនជាតិដើមភាគតិច ។**

២១. ដោយចងចាំក្នុងចិត្តអំពីអវិភាគភាពនៃសិទ្ធិមនុស្សទាំងអស់ គណៈកម្មាធិការជំរុញលើកទឹកចិត្តរដ្ឋភាគីឲ្យពិចារណាអំពីការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងឡាយ ដែលរដ្ឋភាគីនៅមិនទាន់បានផ្តល់សច្ចាប័ននៅឡើយ ជាពិសេស សន្ធិសញ្ញាដែលបញ្ញត្តិរបស់វា មានជាប់ជំពាក់ដោយផ្ទាល់នឹងការរើសអើងពូជសាសន៍ មានជាអាទ៏ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិកម្មករទេសន្តរប្រវេសន៍ និងសមាជិកគ្រួសារទាំងអស់របស់ពួកគេ (១៩៩០) ។

២២. ផ្អែកតាមអនុសាសន៍ទូទៅរបស់ខ្លួនលេខ៣៣ (២០០៩) ស្តីពីការងារតាមដានបន្តដល់សន្និសិទពិនិត្យឡើងវិញក្រុងឌូបៃ គណៈកម្មាធិការផ្តល់អនុសាសន៍ ថា រដ្ឋភាគីផ្តល់ប្រសិទ្ធិភាពអនុវត្តសេចក្តីប្រកាស និងកម្មវិធីសកម្មភាពក្រុងឌូបៃ ដែលបានអនុម័តក្នុងខែ

កញ្ញា ឆ្នាំ ២០០១ ដោយសន្និសិទពិភពលោកប្រឆាំងពូជសាសន៍និយម ការរើសអើង ពូជសាសន៍ ការស្អប់ជនបរទេស និងភាពមិនអនុគ្រោះ ផ្សេងៗទៀតដែលពាក់ពន្ធ័ ដោយគិតអំពីឯកសារស្តីពីលទ្ធផលនៃសន្និសិទត្រួតពិនិត្យឡើងវិញក្រុងឌូបៃ ដែលបានធ្វើឡើងនៅទីក្រុងហ្សឺណែវក្នុងខែមេសា ឆ្នាំ ២០០៩ នៅពេលអនុវត្តអនុសញ្ញានេះ ក្នុងឋានានុក្រមច្បាប់ជាតិរបស់ខ្លួន។ គណៈកម្មាធិការស្នើថា រដ្ឋភាគីគួរដាក់បញ្ចូលក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន នូវព័ត៌មានជាក់លាក់ស្តីពីផែនការសកម្មភាព និងវិធានការផ្សេងទៀតដែលបានចាត់ឲ្យមានឡើង ដើម្បីអនុវត្តសេចក្តីប្រកាស និង កម្មវិធីសកម្មភាពក្រុងឌូបៃនៅថ្នាក់ជាតិ ។

២៣. គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីបន្តធ្វើការពិគ្រោះយោបល់ និងពង្រីកការពិភាក្សារបស់ខ្លួនជាមួយអង្គការសង្គមស៊ីវិលនានា ដែលធ្វើការក្នុងវិស័យការពារសិទ្ធិមនុស្ស ជាពិសេស ក្នុងការប្រយុទ្ធប្រឆាំងការរើសអើងពូជសាសន៍ ទាក់ទងនឹងការរៀបចំរបាយការណ៍តាមកាលកំណត់លើកក្រោយ ។

២៤. គណៈកម្មាធិការជំរុញលើកទឹកចិត្តរដ្ឋភាគីឲ្យពិចារណាអំពីការធ្វើប្រកាសបន្ថែមដូចមានចែងក្នុងមាត្រា១៤ នៃអនុសញ្ញានេះ ។

២៥. គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីផ្តល់សច្ចាប័នលើវិសោធនកម្មមាត្រា៨ កថាខ័ណ្ឌទី៦ នៃអនុសញ្ញានេះ ដែលបានអនុម័តនៅថ្ងៃទី១៥ ខែមករា ឆ្នាំ ១៩៩២ នាសម័យប្រជុំលើកទីដប់បួនរបស់រដ្ឋភាគីនៃអនុសញ្ញានេះ និងបានអនុម័តយល់ព្រមដោយមហាសន្និបាត ក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ៤៧/១១១ ចុះថ្ងៃទី១៦ ខែ ធ្នូ ឆ្នាំ ១៩៩២។ ហេតុដូចនេះ គណៈកម្មាធិការដកស្រង់សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ៦១/១៤៨ ដែលក្នុងនោះ មហាសន្និបាតបានស្នើយ៉ាងទទូចខ្លាំងដល់រដ្ឋភាគីទាំងអស់ឲ្យពន្លឿននីតិវិធីផ្តល់សច្ចាប័ននៅថ្នាក់ជាតិរបស់ខ្លួន ពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មនេះ និងជូនដំណឹងជាលាយលក្ខណ៍អក្សរឲ្យបានឆាប់រហ័សទៅអគ្គលេខាធិការ អំពីការយល់ព្រមធ្វើវិសោធនកម្ម ។

២៦. គណៈកម្មាធិការផ្តល់អនុសាសន៍ថា របាយការណ៍របស់រដ្ឋភាគីត្រូវរក្សាឲ្យមានជាស្រេច និងអាចឲ្យសាធារណៈជនប្រើប្រាស់នៅក្នុងកំឡុងពេលដាក់ជូន ហើយថាសេចក្តីសង្កេតផ្សេងៗរបស់គណៈកម្មាធិការ ទាក់ទងនឹងរបាយការណ៍ទាំងនេះ ក៏ត្រូវផ្សព្វផ្សាយ

ជាសាធារណៈផងដែរ ជាភាសាផ្លូវការ និងភាសាដទៃទៀតដែលបានប្រើប្រាស់ជាទូទៅតាមការគួរ ។

២៧. ដោយកត់សំគាល់ថា រដ្ឋភាគីបានដាក់ជូនឯកសារខ្លឹមសាររួមរបស់ខ្លួនក្នុងឆ្នាំ១៩៩៨រួចហើយ គណៈកម្មាធិការជំរុញលើកទឹកចិត្តរដ្ឋភាគីឲ្យដាក់ជូនសំណៅឯកសារ ដែលបានធ្វើបច្ចុប្បន្នភាពស្របតាមគោលការណ៍ណែនាំស្របគ្នា ស្តីពីការធ្វើរបាយការណ៍ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ជាពិសេស គោលការណ៍ណែនាំស្តីពីឯកសារខ្លឹមសាររួមដែលបានអនុម័តដោយសម័យប្រជុំលើកទីប្រាំរបស់អន្តរគណៈកម្មាធិការស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ដែលបានធ្វើឡើងក្នុងខែមិថុនា ឆ្នាំ២០០៩ (HRI/GEN/2/Rev.6) ។

២៨. អនុលោមតាមមាត្រា៩ កថាខ័ណ្ឌទី១ នៃអនុសញ្ញានេះ និងវិធាន៦៥ នៃនីតិវិធីដែលបានធ្វើវិសោធនកម្មរបស់ខ្លួន គណៈកម្មាធិការស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មាន ក្នុងអំឡុងពេលមួយឆ្នាំចាប់ពីថ្ងៃអនុម័តសេចក្តីសន្និដ្ឋាននេះ ស្តីពីការ ងារតាមដានបន្តដល់អនុសាសន៍ទាំងឡាយ ដែលមានចែងក្នុងកថាខ័ណ្ឌទី១៥, ១៦, ១៧ និងទី១៨ ខាងលើ ។

២៩. គណៈកម្មាធិការមានបំណងផងដែរ ដើម្បីទាញចំណាប់អារម្មណ៍រដ្ឋភាគីទៅលើសារសំខាន់ជាក់លាក់នៃអនុសាសន៍លេខ ១១, ១៣ និង ២០ និងស្នើឲ្យរដ្ឋភាគីផ្តល់ព័ត៌មានលំអិតក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់ខ្លួន ស្តីពីវិធានការជាក់ស្តែងដែលបានចាត់ ដើម្បីអនុវត្តន៍អនុសាសន៍ទាំងនេះ ។

៣០. គណៈកម្មាធិការផ្តល់អនុសាសន៍ថា រដ្ឋភាគីដាក់ជូនរបាយការណ៍តាមកាលកំណត់លើកទី១៤ និងទី១៥ របស់ខ្លួន ក្នុងឯកសារតែមួយ ដែលត្រូវដល់ពេលកំណត់នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ដោយគិតអំពីគោលការណ៍ណែនាំសំរាប់ឯកសារជាក់លាក់ CERD ដែលបានអនុម័តដោយគណៈកម្មាធិការក្នុងសម័យប្រជុំលើកទីចិតសិបមួយរបស់ខ្លួន (CERD/C/ 2007/1) ហើយថា របាយការណ៍នោះត្រូវដោះស្រាយគ្រប់ចំណុចទាំងអស់ ដែលបានលើកឡើងក្នុងសេចក្តីសង្កេតចុងក្រោយនេះ ៕

End.